នស/រកត/០៦០២/១៥៣

# ព្រះរាជក្រឹត្យ
## ស្តីពី
## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។



Downloaded from http://www.khmerlaws.com

# ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.–**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ គ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.–**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ប្រមូលផ្ដុំមន្ត្រីដែលមានទេពកោសល្យបច្ចេកទេសឬការយល់ដឹង ក្នុងការអនុវត្តជាក់ស្ដែង សំរាប់ប្រតិបត្តិការងារជំនាញផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្ដាល និង ខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម មានឧបនិស្ស័យអាចបំពេញមុខតំណែងត្រួតពិនិត្យលើការងារ របស់មន្ត្រីក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេសផងដែរ ។

**មាត្រា ៣.–**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និង ក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៤.–**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមវិស្សាមញ្ញ មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមវិស្ស មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម មាន ១៤ ថ្នាក់ ។ល។

Downloaded from http://www.khmerlaws.com

## ជំពូកទី ២
## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

**មាត្រា ៦.-**

ការប្រលងជ្រើសរើស ក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាប មានសញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ឬមានសញ្ញាប័ត្រដូចកំណត់ខាងលើ ។

## ជំពូកទី ៣
## កម្មសិក្សាសាកល្បង ការតាំងស៊ប់ និងការតែងតាំង

**មាត្រា ៧.-**

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំពេញការងារនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាល របស់ក្រសួង ស្ថាប័នសាមី ទៅតាមជំនាញ ដែលជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវតែងតាំងជាមន្ត្រីបច្ចេកទេសបឋមកម្មសិក្សា ដោយប្រកាស របស់ប្រធានស្ថាប័នទទួលបន្ទុក ។

**មាត្រា ៨.-**

មន្ត្រីបច្ចេកទេសបឋម ដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់ លេខ ១៤ នៃឋានន្តរស័ក្តិទី ៣ ។/.



Downloaded from http://www.khmerlaws.com

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៩.-**

មន្ត្រីបច្ចេកទេសបឋម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំ ទី២ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីស័ស្សនិស្សិតត្រូវលុបឈ្មោះចេញ ។

**មាត្រា ១០.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយដែលបានកំណត់ក្នុងមាត្រា ២ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមបែបបទ ដូចមានកំណត់ក្នុងបញ្ញត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**មាត្រា ១១.-**

មន្ត្រីបច្ចេកទេសបឋម អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

## ជំពូកទី ៤

## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ១២.-**

មន្ត្រីបច្ចេកទេសបឋម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងបទសិក្សាវិជ្ជាជីវៈ
- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវធ្វើតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។/.

Downloaded from http://www.khmerlaws.com

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

**មាត្រា ១៣.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់ របស់មន្ត្រីសាមី ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោម :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

**មាត្រា ១៤.-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌនិងតំណែងកតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាម មាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

មន្ត្រីបច្ចេកទេសបឋមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ល។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.—**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្តក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.—**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៩.—**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកត/០៦០២/១៦៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ : ១៤០ ច.ល
ដើម្បីចម្លងចែរ
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ គាន់**



Downloaded from http://www.khmerlaws.com